# សេចក្តីជូនដំណឹងជាសាធារណៈ

រយៈពេលសម្រាប់ផ្តល់មតិយោបល់សាធារណៈ 15 ថ្ងៃ ដើម្បីពិនិត្យឡើងវិញ លើសេចក្តីព្រាង របាយការណ៍សរុប ស្តីពីការងារអនុវត្តន៍ប្រចាំឆ្នាំ (CAPER) របស់ទីក្រុងឡុងប៊ិច ឆ្នាំ 2017-2018 លើសកម្មភាព និងកម្មវិធីផ្សេងៗ ដែលទទួលបានមូលនិធិ ពី សម្បទានប្លុកអភិវឌ្ឍន៍សហគមន៍ (CDBG) នៃនាយកដ្ឋានអភិវឌ្ឍន៍លំនៅដ្ឋាន និងទីក្រុង (HUD), កម្មវិធីភាពជាដៃគូវិនិយោគ (HOME) និងសម្បទានដំណោះស្រាយសង្គ្រោះបន្ទាន់ (ESG) នឹងចាប់ផ្តើម ពីថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2018 ដល់ថ្ងៃទី 20 ខែធ្នូ ឆ្នាំ 2018 ។ CAPER វាយតម្លៃ លើវឌ្ឍនភាព និងប្រសិទ្ធភាពការងារ របស់ទីក្រុង នៃ ក្នុងកំឡុងឆ្នាំសារពើពន្ធ 2017-18 ដោយផ្តោតលើសមិទ្ធផល នៃយុទ្ធសាស្ត្រ វត្ថុបំណង និងអាទិភាពនានា ដូចមានរាយបញ្ជាក់ នៅក្នុងផែនការរួម សម្រាប់ឆ្នាំសារពើពន្ធ 2018-22 ។ ទីក្រុង នឹងដាក់របាយការណ៍នេះ ជូនទៅ HUD ឱ្យបានមុនថ្ងៃទី 28 ខែធ្នូ ឆ្នាំ 2018 ។ ច្បាប់ចម្លងមួយ នៃរបាយការណ៍ អមដោយមតិយោបល់ពីសាធារណៈជននាពេលបច្ចុប្បន្ន នឹងមានដាក់ផ្សព្វផ្សាយ ជូនដល់សាធារណៈជន នៅការិយាល័យសេវាភូមិដ្ឋាន / មជ្ឈមណ្ឌលធនធាន (100 W Broadway, Long Beach, CA 90802) និងបណ្ណាល័យសាធារណៈ សំខាន់ៗ (101 Pacific Avenue, Long Beach, CA 90802)។ ច្បាប់ចម្លង នៃរបាយការណ៍ ក៏អាចទទួលបានផងដែរ ដោយទាក់ទងទៅ Alem S. Hagos តាមរយៈលេខ (562) 570-7403  ឬដោយចូលទៅមើលផ្នែក “ព័ត៌មានថ្មីៗ បំផុត” នៃគេហទំព័រសេវាអភិវឌ្ឍន៍ ៖ www.lbds.info ។